# វិធានសន្ទានកម្ម
# នៃ អូវីធី ច្បាប់

«**វិធានសន្ទានកម្មនៃអូវីធី ច្បាប់**»គឺជាសមិទ្ធិផលរបស់**ការិយាល័យមេធាវី អូវីធី ឡាយអិន**«**អូវីធី ច្បាប់**»និង**សន្ទានការី អ៊ូច វុទ្ធី**បង្កើតឡើងដើម្បីធ្វើឲ្យងាយស្រួលដល់អតិថិជនប្រើប្រាស់សេវាកម្មសន្ទានកម្មផ្នែកវិវាទរដ្ឋប្បវេណី និងវិវាទពាណិជ្ជកម្ម នៅ**អូវីធី ច្បាប់**។ វិធានសន្ទានកម្មនេះ គឺបង្ហាញពីអ្វីត្រូវធ្វើ គោរពតាមរបៀបនៃការចំណាយ និងកិច្ចប្រតិបត្តិទាំងឡាយពាក់ព័ន្ធនឹងសន្ទានកម្មដែលភាគីវិវាទត្រូវដឹង និងចូលរួមអនុវត្ត ក្នុងគោលបំណងធ្វើឲ្យការដោះស្រាយវិវាទរបស់ពួកគេឆាប់មានដំណោះស្រាយ។ ខ្លឹមសារនៃវិធានមានដូចតទៅ៖

- **វិធានទី១៖ ការតែងតាំងសន្ទានការី**

  ការតែងតាំងសន្ទានការីអាចធ្វើឡើងដោយការ**កំណត់ក្នុងកិច្ចសន្យាជាមុន** ឬ **ព្រមព្រៀង**ដោយគូភាគីវិវាទ**បន្ទាប់ពីវិវាទឬជម្លោះបានកើតឡើង** ។ **សន្ទានការីនៃអូវីធី ច្បាប់** ដែលត្រូវបានតែងតាំងគឺជាមេធាវី ឬមជ្ឈត្តករ **អ៊ូច វុទ្ធី** ដែលអាស្រ័យទៅនឹងប្រភេទវិវាទរដ្ឋប្បវេណី ឬវិវាទពាណិជ្ជកម្ម ។ ភស្តុតាង បញ្ជាក់ពីការតែងតាំងនេះត្រូវធ្វើជាលាយលក្ខណ៍អក្សរដោយមានការចុះហត្ថលេខា ឬផ្តិតម្រាមដៃរបស់គូភាគីវិវាទ និងការចុះហត្ថលេខារបស់សន្ទានការី ។

- **វិធានទី២៖ តួនាទីរបស់សន្ទានការី**

  **សន្ទានការី**ជួយគូភាគីវិវាទក្នុងលក្ខណៈ**អព្យាក្រឹត** ប្រកបដោយ**បច្ចេកទេស** និងប្រកាន់នូវ**ក្រមសីលធម៌**ជាស្តង់ដារអន្តរជាតិ ។ ហេតុនេះ គូភាគីវិវាទត្រូវចូលរួមដោយផ្ទាល់ក្នុងដំណើរការសន្ទានកម្ម ។ អ្នកតំណាង និងជំនួយការរបស់ភាគីវិវាទ មិនត្រូវអនុញ្ញាតជាដាច់ខាត លើកលែងតែកាលៈទេសៈចាំបាច់ និងត្រូវសម្រេចដោយសន្ទានការី ។

- **វិធានទី៣៖ ការចាប់ផ្តើមសន្ទានកម្ម**

  សន្ទានកម្មត្រូវបានចាប់ផ្តើមនៅពេល**ភាគីវិវាទមួយ (ភាគីទាមទារ)** បានដាក់ពាក្យស្នើសុំមកកាន់**អូវីធី ច្បាប់** និងបានបង់ប្រាក់កម្រៃសេវាកម្មនៃអូវីធី ច្បាប់ ព្រមទាំងប្រាក់កក់សម្រាប់បេសកកម្ម (ប្រសិនបើមាន )ដូចមានបញ្ជាក់នៅលើគេហទំព័រ www.ovtlaw.com/contact/application ឬសាកសួរព័តមានតាមរយៈទូរស័ព្ទ ០១២ ៨៨៨ ០២៥ ។ និង**ភាគីវិវាទម្ខាងទៀត (ភាគីឆ្លើយតប)** បានតម្កល់ប្រាក់ក្នុងចំនួនស្មើគ្នា ផងដែរ ។

- **វិធានទី៤៖ កម្រៃ និងការចំណាយសេវាកម្មសន្ធានកម្ម**

**គូភាគីវិវាទ**យល់ព្រមបង់ប្រាក់កម្រៃ និងការចំណាយសេវាកម្មសន្ធានកម្មរបស់**អូវីធី ច្បាប់** ក្នុងចំណែកស្មើគ្នា(៥០%-៥០%) លើកលែងតែភាគីណាមួយរ៉ាប់រងចំណាយទាំងមូល(១០០%) ។

- **វិធានទី៥៖ ការប្រាស្រ័យទាក់ទងរវាងភាគីវិវាទ និង សន្ធានការី**

**សន្ធានការី**ប្រាស្រ័យទាក់ទងជាមួយ**ភាគីវិវាទ**ដោយ**ស្មើភាពគ្នា**ជា**លក្ខណៈរួម** និងដោយ**ឡែកពីគ្នា** ក្នុងគោលបំណងធ្វើឲ្យមានយុត្តិធម៌ និងអាចស្រាយវិវាទបាន ។ ការប្រាស្រ័យទាក់ទងនោះអាចធ្វើដោយផ្ទាល់មាត់ ឬលាយលក្ខណ៍អក្សរ និងគ្រប់មធ្យោបាយទំនាក់ទំនងដែលអាចធ្វើបាន ហើយគ្រប់ភាគីវិវាទត្រូវតែទទួលយកការអញ្ជើញចូលរួមតាមការតម្រូវដោយសន្ធានការី ។

- **វិធានទី៦៖ ការដកខ្លួនពីសន្ធានកម្ម និង ករណីរំលោភវិធានសន្ធានកម្ម**

ករណី**ភាគីវិវាទណាមួយ**សម្រេចដកខ្លួន ឬចាកចេញពីសន្ធានកម្ម ឬរំលោភវិធានសន្ធានកម្មនេះ ដែលធ្វើឲ្យដំណើរការសន្ធានកម្មមិនអាចប្រព្រឹត្តទៅបាន ក្នុងពេលដំណើរការសន្ធានកម្ម ភាគីវិវាទនោះតម្រូវឲ្យទទួលខុសត្រូវលើកម្រៃសេវាកម្មនិងការចំណាយទាំងមូល ១០០% ហើយប្រាក់ទាំងនោះនឹងត្រូវដកហូត ឬមិនបង្វិលសងវិញនូវប្រាក់ដែលភាគីវិវាទនោះបានបង់រួចហើយ ឬបានតម្កល់ទុកពីមុននោះទេ ។

- **វិធានទី៧៖ ការរក្សាការសម្ងាត់**

**គូភាគីវិវាទ** និង**សន្ធានការី** ព្រមទាំង**បុគ្គលទាំងឡាយ**ដែលចូលរួមក្នុងសន្ធានកម្ម ត្រូវរក្សាព័ត៌មាននៃដំណើរការសន្ធានកម្មទុកជាការសម្ងាត់ លើកលែងតែមានការអនុញ្ញាតពីគូភាគីវិវាទ ឬការផ្សព្វផ្សាយរបស់**អូវីធី ច្បាប់** ជាករណីសិក្សា ដោយមិនបញ្ចេញអត្តសញ្ញាណរបស់ភាគីវិវាទ ។

- **វិធានទី៨៖ ការបញ្ចប់ដំណើរការសន្ធានកម្ម**

សន្ធានកម្មត្រូវបានបញ្ចប់ក្នុងករណីណាមួយនៃចំនុចខាងក្រោម៖

-ការព្រមព្រៀងរបស់គូភាគីវិវាទសម្រេចបានដំណោះស្រាយ

-ការដកខ្លួនឬការចាកចេញពីដំណើរការសន្ធានកម្មរបស់ភាគីវិវាទណាមួយ

-ការបញ្ចប់ដំណើរការសន្ធានកម្មពីសន្ធានការីដោយសារការរំលោភវិធានសន្ធានកម្មនេះ របស់ភាគីវិវាទ ។

- **វិធានទី៩៖ ការមិនទទួលខុសត្រូវ**

  **សន្ធានការី** និងបុគ្គលិកនៃ**អូវីធី ច្បាប់** មិនតម្រូវឲ្យទទួលខុសត្រូវក្នុងដំណើរការសន្ធានកម្ម ឬធ្វើជាសាក្សីឲ្យភាគីវិវាទនៅចំពោះមុខយុត្តាធិការណាមួយនោះទេ ហើយរាល់ឯកសាររបស់គូភាគីវិវាទ និងឯកសារពាក់ព័ន្ធផ្សេងៗទៀតក្នុងដំណើរការសន្ធានកម្ម ត្រូវបានចាត់ទុកជារបស់**អូវីធី ច្បាប់** និងមិនត្រូវបានផ្តល់ជាភស្តុតាងសំរាប់យុត្តាធិការផ្សេងទៀតឡើយ ។

«**វិធានសន្ធានកម្ម នៃអូវីធី ច្បាប់**» ឬហៅថា«**វិធាន៥-៥-២៣**» នេះ ត្រូវបានអនុម័ត និងដាក់ឲ្យប្រតិបត្តិ ដោយ**ប្រធានប្រតិបត្តិ** និង**សន្ធានការី** នៃ**អូវីធី ច្បាប់** គិតចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ថ្ងៃសុក្រ ១រោច ខែពិសាខ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

កំពត ថ្ងៃទី ៥ ខែឧសភា ឆ្នាំ២០២៣

**ការិយាល័យមេធាវី អូវីធី ឡាយអិន «អូវីធី ច្បាប់»**

**ប្រ ធា ន ប្រ តិ ប ត្តិ**

**មេធាវី អ៊ូច វុទ្ធី**